00808992

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 11 / 05 / 2012
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E194

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២

**ជូនចំពោះ ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី ÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន ÷** ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ ÷** លំដាប់លំដោយនៃការផ្តល់សក្ខីកម្មរបស់សាក្សីក្នុងសវនាការបច្ចុប្បន្ននៃសំណុំរឿង ០០២/០១

បន្ថែមទៅនឹងអនុស្សរណៈរបស់ខ្លួន ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារលេខ E172) និងថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ (ឯកសារលេខ E172/10), អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់ព័ត៌មានថ្មីទាក់ទងនឹងលំដាប់លំដោយនៃការកោះហៅសាក្សីឱ្យផ្តល់សក្ខីកម្មដើម្បីជាប្រយោជន៍ដល់សាធារណជន។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យញត្តិរបស់សហព្រះរាជអាជ្ញា សុំឱ្យផ្តល់អាទិភាពចំពោះសក្ខីកម្មរបស់សាក្សីដែលមានវ័យចំណាស់ (ឯកសារលេខ E188 និងឧបសម្ព័ន្ធសម្ងាត់លេខ E188.1) ដែលបានស្នើសុំអង្គជំនុំជម្រះឱ្យផ្តល់អាទិភាពដល់ការផ្តល់សក្ខីកម្មរបស់សាក្សីមួយចំនួន ដោយផ្អែកលើវ័យចំណាស់របស់សាក្សី និងស្តាប់សក្ខីកម្មរបស់ពួកគាត់ ដោយផ្អែកលើអង្គហេតុទាំងស្រុងដែលមានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២។ អង្គជំនុំជម្រះសាលាដំបូងក៏បានពិចារណាលើព័ត៌មានដែលខ្លួនទទួលបានពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងនឹងសុខភាព និងពេលវេលាដែលសាក្សីទាំងនេះអាចចូលផ្តល់សក្ខីកម្មបាន។

នៅពេលបន្តសវនាការនៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ បន្ទាប់ពីសម្រាករួច អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សី ពាន ឃាន (TCW-504)។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់សក្ខីកម្មរបស់សាក្សីផ្សេងៗទៀត តាមលំដាប់លំដោយប្រមាណដូចខាងក្រោម ៖

TCW-487 *(ក្រសួង ៖ ក្រសួងការបរទេស, មន្ទីរ ប១)*

TCW-604 *(អង្គហេតុទាំងអស់នៃសំណុំរឿង ០០២)*

TCW-583 *(អង្គហេតុទាំងអស់នៃសំណុំរឿង ០០២)*

TCW-488 *(វចនាសម្ព័ន្ធរដ្ឋបាល ៖ មជ្ឈិម)*

TCW-323 *(ក្រសួង ៖ ក្រសួងការបរទេស, មន្ទីរ ប១)*

អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងដល់ភាគីទាំងអស់បន្ថែមទៀតថា អង្គជំនុំជម្រះអាចនឹងស្តាប់សក្ខីកម្មរបស់សាក្សី TCW-321 និងសាក្សី TCW-797 ប្រសិនបើមានពេលវេលាទំនេរដោយមិនបានគ្រោងទុកនៅក្នុងកម្មវិធីធ្វើសវនាការ។ អង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់សក្ខីកម្មរបស់សាក្សីទាំងពីរទាក់ទងនឹងអង្គហេតុទាំងអស់ ដែលមានចែងក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២។

ការស្តាប់សក្ខីកម្មរបស់សាក្សីផ្សេងៗទៀត ដែលមានរាយនាមនៅក្នុងឯកសារលេខ E172 នឹងត្រូវរៀបចំនៅពេលក្រោយទៀត បន្ទាប់ពីមានការបញ្ជាក់ពីពេលវេលានៃការចូលផ្តល់សក្ខីកម្មរបស់សាក្សីទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូងសូមរំឭកថា សាក្សីណាដែលមានឈ្មោះនៅក្នុងឯកសារលេខ E172 អាចនឹងត្រូវកោះហៅឱ្យផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ ហើយថា អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការកែប្រែលំដាប់លំដោយខាងលើនេះ នៅពេលណាការផ្លាស់ប្តូរទាំងនេះធ្វើឱ្យការគ្រប់គ្រងតុលាការកាន់តែមានប្រសិទ្ធភាព។ នៅពេលជនជាប់ចោទសម្រេចចិត្តផ្តល់សក្ខីកម្ម ឬនៅពេលពាក់ព័ន្ធនឹងបញ្ហាសុខភាពរបស់សាក្សី ឬការកែប្រែណាមួយដែលធ្វើឱ្យការគ្រប់គ្រងសវនាការមានប្រសិទ្ធភាពនោះ អង្គជំនុំជម្រះសាលាដំបូងក៏អាចស្តាប់សក្ខីកម្មរបស់សាក្សីក្នុងរយៈពេលតែកន្លះថ្ងៃនៅពេលចាំបាច់។